FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ



ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# កង្វះផូស្វ័រ

***តួនាទី និងចលភាពនៃផូស្វ័រ***

ផូស្វ័រមានសារៈសំខាន់ណាស់សម្រាប់ការផ្ទុក និងការផ្ទេរថាមពលនៅក្នុងរុក្ខជាតិ។ ផូស្វ័រមានចលនានៅក្នុងរុក្ខជាតិ ហើយជំរុញការបែកគុម្ព ការអភិវឌ្ឍន៍ឫស ការចេញផ្ការហ័ស និងការទុំ។ ជាពិសេស វាមានសារៈសំខាន់ណាស់នៅក្នុងដំណាក់កាលលូតលាស់ដំបូង។

***រោគសញ្ញានៃកង្វះផូស្វ័រ និង ឥទ្ធិពលទៅលើការលូតលាស់***

រុក្ខជាតិតឿមានពណ៌បៃតងក្រមៅដោយមានស្លឹកឈរត្រង់ ហើយកាត់បន្ថយការបែកគុម្ព ។

***មូលហេតុនៃកង្វះ ផូស្វ័រ***

- កម្លាំងផ្គត់ផ្គង់ផូស្វ័រ ដែលមានស្រាប់របស់ដី មានកម្រិតខ្សោយ
- ការប្រើប្រាស់ជីផូស្វ័រ ក្នុងបរិមាណមិនគ្រប់គ្រាន់
- ប្រសិទ្ធិភាពទាបនៃជីផូស្វ័រដែលបានប្រើប្រាស់ ដោយសារតែសមត្ថភាពចាប់យកផូស្វ័រនៅក្នុងដី ឬការបាត់បង់តាមរយៈសំណឹក (ចំពោះតែស្រូវចំការតែប៉ុណ្ណោះ) មានកម្រិតខ្ពស់
- ការប្រើប្រាស់ជីអាសូតច្រើនលើសលុប រួមជាមួយការប្រើប្រាស់ជីផូស្វ័រ ក្នុងបរិមាណមិនគ្រប់គ្រាន់
- ភាពខុសគ្នារបស់ពូជស្រូវ ចំពោះភាពមិនធន់ទ្រាំទៅនឹងកង្វះផូស្វ័រ និងការឆ្លើយតបទៅនឹងជីដែលមានជាតិផូស្វ័រ
- របៀបដាំដុះដំណាំ (កង្វះផូស្វ័រកើតមានច្រើន ទៅលើដំណាំស្រូវដាំដោយការព្រោះគ្រាប់ ដែលជាកន្លែងដែលដង់ស៊ីតេដំណាំស្រូវមានកម្រិតខ្ពស់ ហើយប្រព័ន្ធឫសស្ថិតនៅរាក់ៗ)។

***ពពួកដីដែលងាយប្រឈមនឹងកង្វះផូស្វ័រ***

- ប្រភេទដីសាច់គ្រើមដែលផ្ទុកបរិមាណសារធាតុសរីរាង្គតិចតួច និងផូស្វ័របម្រុងទុករបស់ដីមានចំនួនតិច
- ដីបាស ដីប្រៃ និងដីកាល់គែរ

- ដីភ្នំភ្លើង (ដែលចាប់យកផូស្វ័រយ៉ាងខ្លាំង) ដីមមោក និងដីអាស៊ីតស៊ុលហ្វាត។

*ការកើតឡើងនៃកង្វះផូស្វ័រ*

- ការប្រើប្រាស់ជីអាសូត ឬអាសូត+ប៉ូតាស់ ក្នុងបរិមាណច្រើនលើសលុប ដោយប្រើប្រាស់ជីផូស្វ័រក្នុងបរិមាណមិនគ្រប់គ្រាន់
- ***ឥទ្ធិពលនៃការពន្លិចទឹកទៅលើភាពសេរី និងការស្រូបយកផូស្វ័រ***
- ការពន្លិចទឹកទៅលើដីស្ងួត ធ្វើឲ្យភាពសេរីរបស់ផូស្វ័រមានការកើនឡើង។

*ការគ្រប់គ្រងផូស្វ័រ*

ផូស្វ័រទាមទាឲ្យមានយុទ្ធសាស្ត្រគ្រប់គ្រងក្នុងរយៈពេលយូរអង្វែង ។ ការប្រើប្រាស់ជីផូស្វ័របានបន្សល់ឥទ្ធិពលយូរអង្វែង ដែលអាចមានរយៈពេលជាច្រើនឆ្នាំ ។ ការគ្រប់គ្រងត្រូវតែផ្តោតទៅលើការបង្កើន និងការថែរក្សាកម្រិតផូស្វ័រសេរីរបស់ដី ឲ្យមានបរិមាណគ្រប់គ្រាន់ ដើម្បីធ្វើឲ្យប្រាកដថា ការផ្គត់ផ្គង់ផូស្វ័រមិនបានកម្រិតទៅលើការលូតលាស់ ទិន្នផលគ្រាប់ និងប្រសិទ្ធិភាពនៃការប្រើប្រាស់ជីអាសូតឡើយ ។